# តម្លៃគុណភាពមាននៅក្នុង សាលារៀនរដ្ឋ NSW

## Values in NSW public schools

ព័ត៌មានសំរាប់មាតាបិតា
និងអ្នកមើលថែ

Information for
parents and
carers

យកចេញពីសេចក្តីថ្លែងសុន្ទរកថារបស់រដ្ឋមន្ត្រីនៅ:
https://www.det.nsw.edu.au/policies/student_serv/student_welfare/valu_scool/pd_05131_Values.pdf

NEW SOUTH WALES
DEPARTMENT
OF EDUCATION
AND TRAINING

Khmer

# ដំណោះស្រាយរបស់រដ្ឋ NSW ចំពោះតម្លៃគុណភាព និងតម្លៃគុណភាពនៃការអប់រំមាននៅក្នុងសាលារៀនរដ្ឋ

## តម្លៃគុណភាព

សាលារៀនរដ្ឋ NSW តែងបានបង្ហាត់បង្រៀនអំពីតម្លៃគុណភាពដែលជាមូលដ្ឋាននៃច្បាប់ ទំនៀមទំលាប់ ហើយយកចិត្តទុកដាក់ចំពោះអ្នកដទៃក្នុងសង្គមរបស់យើង។

សាលារៀននៅរដ្ឋ NSW រួមចំណែកជាមួយគ្រួសារ និងសហគមន៍នូវការទទួលខុសត្រូវក្នុងការបង្ហាត់បង្រៀនអំពីតម្លៃគុណភាព។ ក្នុងខណៈតម្លៃគុណភាពត្រូវបានរៀនជាចម្បងបំផុតនៅតាមផ្ទះ ហើយបានកែសំរួលតាមរយៈទំនាក់ទំនង និងការពិសោធន៍ក្នុងជីវិតនុះមាតាបិតា ហើយនិងសហគមន៍មានក្តីសង្ឃឹមយ៉ាងលើសលប់អំពីតម្លៃគុណភាពដែលមានរួមគ្នា ក៏បានបង្ហាត់នៅសាលារៀនផងដែរ។

ការចង្អុលបង្ហាញនូវតម្លៃគុណភាពទាំងនេះនៅគ្រប់វិស័យអប់រំសាធារណៈ គឺជាគោលបំណង ហើយនិងវិធានការណ៍នៃការសំរេចជោគជ័យសំរាប់សាលារៀនរដ្ឋ។

## តម្លៃគុណភាពនៅក្នុងការអប់រំ

សាលារៀនរដ្ឋបង្ហាត់បង្រៀនអំពីតម្លៃគុណភាពទាំងឡាយ រាប់បញ្ចូលទាំងតម្លៃដែលគាំទ្រការរៀនសូត្រ។ សាលារៀនរដ្ឋក៏ផ្តល់ឲ្យសិស្សផងដែរនូវលទ្ធភាពក្នុងកាន់ស្វែងយល់អំពីតម្លៃគុណភាព ដែលមាននៅពីក្រោយឥរិយាបទនៃសហគមន៍នានាចំពោះបញ្ហានយោបាយ ហើយនិងចំណាប់អារម្មណ៍ផ្នែកសង្គម។

តម្លៃគុណភាពត្រូវបានបង្ហាត់បង្រៀនយ៉ាងច្បាស់លាស់នៅក្នុងថ្នាក់រៀន ហើយនិងតាមរយៈសកម្មភាព ហើយនិងទំនាក់ទំនងរវាងសាលារៀន និងសហគមន៍របស់ខ្លួន។

នៅសាលារៀន តម្លៃគុណភាពសំខាន់ចាំបាច់មានឥទ្ធិពលទៅលើរបៀបដែលប្រជាជនទាក់ទងគ្នា ធ្វើការជាមួយគ្នា ហើយនិងការធ្វើសេចក្តីសម្រេច។ ទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញនូវគោលនយោបាយ និងនិតីវិធីរបស់សាលារៀន និងក្រសួងអប់រំ។

## តម្លៃគុណភាពសំខាន់ចាំបាច់

រដ្ឋាភិបាលទទួលស្គាល់នូវភាពសំខាន់នៃតម្លៃគុណភាពសំខាន់ចាំបាច់ដូចតទៅនេះដល់សហគមន៍។ តម្លៃគុណភាពទាំងនេះជាតំណាងនៃឆន្ទះ និងជំនឿនៃសហគមន៍អូស្ត្រាលីទាំងមូល រាប់បញ្ចូលទាំងចំណាប់អារម្មណ៍ចំពោះសមធម៌ ភាពល្អប្រសើរ និងផ្សព្វផ្សាយនូវទឹកចិត្តល្អ សង្គមស៊ីវិល និងយុត្តិធម៌។ ទាំងនេះមានលក្ខណៈរួមក្នុងចំណោមទស្សនៈទូទៅនៃអ្នកដែលមិនទាក់ទិននឹងសាសនា ហើយនិងអ្នកកាន់សាសនា ដែលគេឃើញមាននៅក្នុងវប្បធម៌ភាគច្រើន។

តម្លៃគុណភាពសំខាន់ចាំបាច់ទាំងនេះមានៈ

**សេចក្តីសុចរិត** មានភាពស្មោះត្រង់ ហើយគួរឲ្យទុកចិត្តបានយ៉ាងទៀងទាត់។

**ឧត្តមភាព** ខំប្រឹងប្រែងដើម្បីបានសំរេចគោលបំណងខ្ពង់ខ្ពស់ផ្ទាល់ខ្លួន គ្រប់ទាំងចំណុចសំខាន់ៗនៃការរៀនសូត្រ ព្រមទាំងកិច្ចការបុគ្គលផ្ទាល់ និងកិច្ចការសហគមន៍ ការងារ និងចំណេះដឹងពេញមួយឆាកជីវិត។

**សេចក្តីគោរព** មានការគោរពចំពោះខ្លួនឯង និងចំពោះអ្នកដទៃ ចំពោះសមត្ថកិច្ចផ្លូវច្បាប់ និងចំពោះអ្វីដែលមានភាពផ្សេងៗគ្នាក្នុងសង្គមអូស្ត្រាលី ហើយទទួលស្គាល់នូវសិទ្ធិរបស់អ្នកដទៃដែលមានការយល់ខុសគ្នា ឬផ្ទុយគ្នា។

**ការទទួលខុសត្រូវ** មានស្មារតីទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនផ្ទាល់ ឬសហគមន៍ ចំពោះខ្លួនឯង អ្នកដទៃ និងបរិដ្ឋាន។

**សហប្រតិបត្តិការ** ធ្វើការរួមគ្នា ដើម្បីសំរេចគោលដៅរួម ផ្តល់នូវការទ្រទ្រង់ចំពោះអ្នកដទៃ ហើយចូលរួមក្នុងដំណោះស្រាយភាពផ្ទុយគ្នាដោយសន្តិភាព។

**ការចូលរួមជាមួយ** ជាបុគ្គល ហើយជាសមាជិកក្រុមដែលមាន មានការប្រុងប្រៀបជាមុន ហើយប្រយោជន៍ មានមោទនភាពក្នុងការចូលរួមវិភាគទានចំពោះភាពសម្បូណ៌សប្បាយផ្នែកសង្គម និងសេដ្ឋកិច្ចក្នុងសហគមន៍ និងប្រទេសជាតិ។

**ការយកចិត្តទុកដាក់** ការចាប់អារម្មណ៍អំពីសុខុមាលភាពខ្លួនឯង ហើយនិងអ្នកដទៃ បង្ហាញនូវការយល់ពីអារម្មណ៍អ្នកដទៃ ហើយធ្វើដោយចិត្តមេត្តាធម៌។

**ភាពយុត្តិធម៌** មានភាពទ្រទ្រង់នូវគោលការណ៍យុត្តិធម៌ ក្នុងសង្គម ហើយប្រឆាំងនឹងការវិនិច្ឆ័យមិនសមហេតុសមផល ភាពទុច្ចរិត និងអយុត្តិធម៌។

**ប្រជាធិបតេយ្យ** ទទួលស្គាល់ហើយ ជួយផ្សព្វផ្សាយនូវសិទ្ធសេរីភាព ហើយនិងការទទួលខុសត្រូវក្នុងឋានៈជាពលរដ្ឋអូស្ត្រាលី។